**BMI0162**

# សម្ភាសន៍ជាមួយឈ្មោះ ប៊ូ ម៉ៅ ភេទប្រុស អាយុ៥៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័តតំបន់

## រស់នៅភូមិស្រែះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## សម្ភាសន៍ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៥៥:៤៥

## សរុបទំព័រៈ ២៦

វណ្ណៈ　អញ្ចឹងថ្ងៃនេះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ហើយខ្ញុំឈ្មោះសុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកដល់ភូមិឃុំរបស់ពូគឺចង់ដឹងរឿងរ៉ាវបងប្អូនដែលរស់នៅ ហើយបានឆ្លងកាត់សម័យ៣ឆ្នាំ ពី៧៥ដល់៧៩ ជាពិសេសគឺទាក់ទងនឹងអាងត្រពាំងថ្ម ហើយនឹងមានការលើកវែកយ៉ាងម៉េចខ្លះ ហើយមានសភាពយ៉ាងម៉េចខ្លះ នៅពេលហ្នឹង ហើយចង់ដឹងប្រវត្តិទាំងអស់ហ្នឹង ទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮដែរ ព្រោះថាយើងបន្តិចទៀតទៅយើងមិនមែនជីវិតអមតៈទេ យើងស្លាប់ទៅបាត់ហើយ អញ្ចឹងយើងសម្តីអស់ ហ្នឹងដែលខ្ញុំបានជួបជាមួយពូហ្នឹងក្មេងជំនាន់ក្រោយក៏វាបានដឹងដែរ អញ្ចឹងពូអត់មានថាអីទេ ដូចថាទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮ ពូអត់មានថាអីទេពូ?

ម៉ៅៈ　ខ្ញុំអត់មានថាអីទេ ប៉ុន្តែប្រវត្តិចល័តត្រពាំងថ្មបើតាមនិយាយទៅខ្ញុំអ្នកសំរោង ។

វណ្ណៈ　អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

ម៉ៅៈ　ខ្ញុំឈ្មោះ ប៊ូ ម៉ៅ ។

វណ្ណៈ　ពូមានអាយុប៉ុន្មានហើយ?

ម៉ៅៈ　ខ្ញុំអាយុ៥៥ឆ្នាំហើយ ។

វណ្ណៈ　ប្រពន្ធពូ?

ម៉ៅៈ　សិដល ។

វណ្ណៈ　គាត់អាយុប៉ុន្មានដែរ?

ម៉ៅៈ　អាយុ៥៤ឆ្នាំ ។

វណ្ណៈ　សព្វថ្ងៃពូមានកូនប៉ុន្មាននាក់?

ម៉ៅៈ　កូន៦នាក់ ។

វណ្ណៈ ឪពុកពូឈ្មោះអីដែរ?

ម៉ៅៈ ឈ្មោះដា ឡូយ ។

វណ្ណៈ ចុះម្ដាយ?

ម៉ៅៈ ម្ដាយឈ្មោះ ពៅ លួន ។

វណ្ណៈ សព្វថ្ងៃគាត់ស្លាប់ឬក៏នៅ?

ម៉ៅៈ ឪពុកស្លាប់ ។

វណ្ណៈ ម្ដាយនៅរស់ទេ?

ម៉ៅៈ បាទ!

វណ្ណៈ បងប្អូនបង្កើតពូប៉ុន្មាននាក់?

ម៉ៅៈ ៩នាក់ ។

វណ្ណៈ នៅសល់ប៉ុន្មានសព្វថ្ងៃ?

ម៉ៅៈ នៅសល់ទាំងអស់គ្នា ។

វណ្ណៈ ចុះស្រុកកំណើតរបស់ពូនៅណាដែរ?

ម៉ៅៈ នៅនេះរហូត ។

វណ្ណៈ គេហៅភូមិអី?

ម៉ៅៈ ភូមិស្រែះ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

វណ្ណៈ ស្រែះលិចឬក៏ស្រែះកើត?

ម៉ៅៈ ស្រែះខាងកើត ។

វណ្ណៈ ស្រុកព្រះនេត្រព្រះ កាលពីជំនាន់សម័យសីហនុអីខេត្តបាត់ដំបងទេ?

ម៉ៅៈ បាទ! ខេត្តបាត់ដំបង ។

វណ្ណៈ តែឥឡូវខេត្តបន្ទាយមានជ័យ?

ម៉ៅៈ បាទ! គេដូរមកបន្ទាយមានជ័យ ។

វណ្ណៈ អញ្ចឹងកាលពីជំនាន់ដើមពូមានបានរៀនសូត្រដែរ?

ម៉ៅៈ ខ្ញុំបើនិយាយទៅខ្ញុំអត់មានបានរៀនទេ ។

វណ្ណៈ អត់បានរៀនសោះ?

ម៉ៅៈ បាទ!

វណ្ណៈ អត់ចេះហ្នឹងអញ្ចឹង?

ម៉ៅៈ	ទេសព្វថ្ងៃអាចចេះ កាលពីសម័យនៅនារីគឺខ្ញុំអាចចេះមើលបាន សរសេរបាន ។

វណ្ណៈ	ប៉ុន្តែកាលពីដើមអត់មានបានរៀនទេ?

ម៉ៅៈ	អត់បានរៀនទេ ។

វណ្ណៈ	ចុះពូ មូលហេតុអីបានជាអត់បានរៀន?

ម៉ៅៈ	ក្រពេក ក្រណាស់ពេលនោះ ឪពុកម្តាយខ្ញុំគាត់ក្រណាស់ ។

វណ្ណៈ	អញ្ចឹងដល់ពេលពូអត់បានរៀនអញ្ចឹង ពូជួយធ្វើការងារឪពុកម្តាយធ្វើស្រែចំការទៅ?

ម៉ៅៈ	បាទ!

វណ្ណៈ	អញ្ចឹងរហូតដល់ឆ្នាំ៧០ ឆ្នាំរដ្ឋប្រហារហ្នឹងពូដឹងទេកាលហ្នឹង សម័យសង្គ្រាមឆ្នាំរដ្ឋប្រហារ?

ម៉ៅៈ	កាលសម័យរដ្ឋប្រហារខ្ញុំនៅក្មេងស៊ើរដែរ កាលហ្នឹងនៅនេះរហូតដដែល ។

វណ្ណៈ	ចុះដឹងថាទាហានព្រៃ ដូចថាកាលហ្នឹងពួកបង១ដូចថាធំៗអាយុ១៧-១៨ឆ្នាំគេចូល ពេលដែលរដ្ឋប្រហារហើយមានការឈឺចាប់នឹងជាមួយលន់ នល់ មានចូលព្រៃម៉ាគីដើម្បីប្រឆាំងជាមួយទាហានលន់ នល់ កាលហ្នឹងពូដឹងទេ?

ម៉ៅៈ	កាលនោះដឹង តែនៅនេះអត់មានទេ អត់មានអ្នកប្រឆាំងរត់ចោលទេ មានត្រឹមព្រៃយើងមានត្រឹមយើងចូលឡើងមកនេះ ត្រឹមព្រៃចូលមកនេះពីឆ្នាំ៧៥ មានពួកខ្មែរក្រហមមួយក្រុមចូលមកនេះ តែទាហានយើងវ៉ៃឡើងចូល ។

វណ្ណៈ	វ៉ៃចុះឡើងៗ?

ម៉ៅៈ	បាទ! វ៉ៃចុះឡើង ។

វណ្ណៈ	ចុះមានយន្តហោះទម្លាក់គ្រាប់បែកទេ?

ម៉ៅៈ	មាន យន្តហោះទម្លាក់ឡើងរណ្តៅធំៗណាស់ ។

វណ្ណៈ	ចុះមាន ដូចថាត្រូវប្រជាជនស្លាប់ទេភូមិនេះ?

ម៉ៅៈ	អត់មានទេ មានតែស្លាប់ខ្មែរក្រហមម្នាក់ ។

វណ្ណៈ	អញ្ចឹងមានទម្លាក់គ្រាប់បែកដែរ?

ម៉ៅៈ	មាន រណ្តៅឡើង៥-៦ម៉ែត្រ ខ្ញុំមិនសូវស្គាល់ទេកាលហ្នឹង ។

វណ្ណៈ	អញ្ចឹងគ្រាប់បែកមានទូទាំងប្រទេសហើយកាលជំនាន់ហ្នឹង?

ម៉ៅៈ	អត់មានអំបែងទេ តែដីហ្នឹងលុបបាក់អស់ហើយ ដីប៉ុន្មានប្រហែលជា៥-៦ម៉ែត្រ ជិតប៉ុនស្រះមួយ ។

វណ្ណៈ	អញ្ចឹងភ័យខ្លាចទេកាលហ្នឹង?

ម៉ៅៈ	ខ្លាចដែរហ្នឹង ត្អារត់ទៅនៅក្រោម ហើយត្រូវខែវស្សាជន់សុទ្ធតែទឹក ។

វណ្ណៈ	ចុះដល់ពេលចលនាខ្មែរក្រហមវ៉ៃឈ្នះទាហានលន់ នល់ នៅឆ្នាំ៧៥ ខ្មែរក្រហមកាន់ទូទាំងប្រទេសហ្នឹង តើប្រជាជននៅក្នុងភូមិហ្នឹងគេជម្លៀសទៅណាដែរ ឬក៏នៅនេះ?

ម៉ៅៈ	អត់មានទៅណាផង ។

វណ្ណៈ	អញ្ចឹងអត់មានជម្លៀសទេ?

ម៉ៅៈ	បាទ! អត់មានជម្លៀសទេ ។

វណ្ណៈ	ចុះដល់ពេលខ្មែរក្រហមចូលមក គេឲ្យពូទៅខាងណា ទៅកងចល័តឬក៏ទៅណា?

ម៉ៅៈ	ទៅកងចល័ត ។

វណ្ណៈ	កាលហ្នឹងពូអាយុប៉ុន្មានហើយទៅកងចល័តហ្នឹង?

ម៉ៅៈ	ប្រហែលអាយុ១៨ហើយ កាលហ្នឹងមិនដឹងជាប៉ុន្មានទេខ្ញុំមិនច្បាស់ដែរ ។

វណ្ណៈ	ពូមានដែលបានទៅភ្នំពេញទេ?

ម៉ៅៈ	អត់ដែលបានទៅទេ ។

វណ្ណៈ	កងចល័តហ្នឹងកងចល័តស្រុកឬកងចល័តភូមិ?

ម៉ៅៈ	កងចល័តតំបន់ ។

វណ្ណៈ	អញ្ចឹងមានកងចល័តភូមិ ស្រុក ហើយនឹងតំបន់?

ម៉ៅៈ	បាទ!

វណ្ណៈ	តំបន់ហ្នឹងតំបន់ប៉ុន្មាន?

ម៉ៅៈ	តំបន់៥ ។

វណ្ណៈ	កាលហ្នឹងកងចល័តតំបន់៥ ពូចូលទៅដំបូងនៅឆ្នាំ៧៥ហ្នុង?

ម៉ៅៈ	បាទ!

វណ្ណៈ	កាលចូលដំបូងនៅឆ្នាំ៧៥ហ្នឹង ពូចូលទៅជួបពីណាខ្លះ ដូចថាប្រធានពីណាគេ?

ម៉ៅៈ	ចូលទៅមានពួកតាម៉ោង ហើយនឹង តាវ៉ាល់ ហ្នឹងហើយប្រធានដែលនៅគ្រប់គ្រង ។

វណ្ណៈ	គាត់មានតួនាទីអី តាម៉ោង ហើយនឹង តាវ៉ាល់?

ម៉ៅៈ	គាត់ក្តាប់រួមទាំងអស់ បើនិយាយទៅពីដើមគាត់អតីត ។

វណ្ណៈ	តាំងពីដើម៧៥មក?

ម៉ៅៈ	បាទ! គាត់ក្តាប់យោធាមួយស្រុក ដល់ពេលហើយគេដកគាត់កាន់ចល័តតំបន់ ។

វណ្ណៈ	អញ្ចឹងតាម៉ោង ហើយនឹង តាវ៉ាល់ ដំបូងគាត់កាន់យោធា?

ម៉ៅៈ បាទ!

វណ្ណៈ ចុះដល់ឆ្នាំណាគេឲ្យកាន់ចល័តតំបន់វិញ?

ម៉ៅៈ ឆ្នាំ៧៦អីហ្នឹង គាត់កាន់យោធាបានតែមួយឆ្នាំហ្នឹង កាន់យោធាស្រុក ដល់ក្រោយមកដក កាន់ចល័តតំបន់វិញ ។

វណ្ណៈ កាន់ចល័តតំបន់វិញ?

ម៉ៅៈ បាទ!

វណ្ណៈ តាមពិតទៅតួនាទីគាត់ដូចជាគណៈតំបន់ឬក៏គណៈស្រុក?

ម៉ៅៈ គណៈស្រុកទេ ។

វណ្ណៈ កាលពូនៅកងចល័តតំបន់ហ្នឹង មានគ្នាប៉ុន្មាននាក់ទាំងអស់?

ម៉ៅៈ ច្រើនណាស់លោកគ្រូ ដកចេញពីស្រុកទៅនៅគ្រប់គ្រងនៅត្រពាំងថ្ម បើគិតទៅរាប់ម៉ឺននាក់

វណ្ណៈ ប៉ុន្តែឥឡូវនិយាយពីពូចូលទៅចល័តតំបន់សិន ក្នុងកងរបស់ពូមានគ្នាប៉ុន្មាននាក់?

ម៉ៅៈ កងខ្ញុំមាន៣០០នាក់ ម៉ាវរៈបញ្ចូល គេប្រាប់បញ្ចូលឲ្យទៅនៅលើកទំនប់ ។

វណ្ណៈ កាលហ្នឹងពូអត់ទាន់មានតួនាទីទេ?

ម៉ៅៈ អត់មានអីទេ ។

វណ្ណៈ ពីណាប្រធានវរៈ?

ម៉ៅៈ ប្រធានវរៈរបស់គេ កាលនោះគេអត់ទាន់មានរៀបទេខ្ញុំទៅដល់មុនដំបូង ខ្ញុំទៅដល់ដំបូងគេ រៀបឲ្យពួកយោធាមកគ្រប់គ្រង អ៎! មិនមែនយោធាទេឲ្យមេឃុំអ្នកគ្រប់គ្រង គណៈឃុំ ។

វណ្ណៈ គណៈឃុំហ្នឹងពីណាគេ?

ម៉ៅៈ ឈ្មោះ តាផន នៅឃុំព្រះនេត្រព្រះមកនៅក្តាប់បណ្តោះអាសន្នសិន ។

វណ្ណៈ ចុះពូធ្វើនៅហ្នឹងពី៧៥ដល់ប៉ុន្មានបានពូមានតួនាទីឡើង គេឲ្យពូកាន់រហូតដល់៣០០នាក់ ហ្នឹង?

ម៉ៅៈ ដូចជាឆ្នាំ៧៧ ក្រោយមកគេរៀបកសាងកម្លាំងប្រភេទជឿនលឿន ប្រលងប្រណាំងគ្នាហ្នឹង ខ្ញុំរៀបចំទៅគេឲ្យខ្ញុំគ្រប់គ្រង អ្នកណាដែលធ្វើជឿនលឿន ឧទាហរណ៍អញ្ចឹងលោកគ្រូ ខ្ញុំជម្រាប ឧទាហរណថាលើកទំនប់មួយគេដាក់ផែនការមួយអាទិត្យតើយើងធ្វើឬអត់ លឿន អត់ ខាងនោះកងខាងនោះក៏មួយអាទិត្យ ដល់ពេលយើងធ្វើបានទៅគេឲ្យយើងកងកម្លាំង ពិសេស ហើយគេរៀបឲ្យយើង ថាយើងដឹកនាំធ្វើបាន សម្រេចផែនការឲ្យគេបាន ។

វណ្ណៈ ឋានៈយ៉ាងម៉េចទៅ ប្រធានយ៉ាងម៉េចទៅ?

ម៉ៅៈ ខ្ញុំគេឲ្យកាន់វរៈ ។

វណ្ណៈ កាន់វរៈសេនាធំឬក៏តូច?

ម៉ៅៈ វរៈសេនាធំ ។

វណ្ណៈ មានគ្នា៣០០នាក់?

ម៉ៅៈ បាទ!

វណ្ណៈ ប៉ុន្តែ៣០០នាក់ហ្នឹងយើងវរៈមែន តែមិនមែនយោធាទេ?

ម៉ៅៈ មិនមែនទេ ដូចថាអ្នកស្រុក... ។

វណ្ណៈ ប្រជាជន?

ម៉ៅៈ ប្រជាជន ប៉ុន្តែដូចថានៅចល័តយូទៅ ហើយយើងធ្វើបានលឿនគេជ្រើសរើសយកតែអ្នកដែលលឿនៗរៀបចំកម្លាំងពិសេសរបស់គេ អាកម្លាំងពិសេសបងប្អូនអាខ្មោចហ្នឹងឯងត្រពាំងហ្នឹងគេរុញយើងដាក់ឲ្យធ្វើហ្នឹង ។

វណ្ណៈ កាលហ្នឹងកាន់ប្រជាជន?

ម៉ៅៈ បាទ!

វណ្ណៈ កាន់ប្រជាជននៅភូមិណា?

ម៉ៅៈ មិនដឹងជាកាន់នៅណាទេ មិនដឹងដែរហ្នឹង កាលហ្នឹងគេប្រមូលបគ្រប់ឲ្យ អ្នកណាដែលកម្លាំងរាងមាំទាំទៅគេបញ្ជូនមក ។

វណ្ណៈ តែពូដឹកនាំកម្លាំង៣០០នាក់ហ្នឹងនៅកន្លែងណា ទីតាំង?

ម៉ៅៈ នៅភូមិរោគ ។

វណ្ណៈ ភូមិរោគនៅ....?

ម៉ៅៈ នៅស្រុកភ្នំស្រុក ។

វណ្ណៈ កាលហ្នឹងពីណាគណៈស្រុកភ្នំស្រុក?

ម៉ៅៈ ខ្ញុំអត់ស្គាល់ទេ មិនដឹងពីណាគណៈស្រុកភ្នំស្រុកទេ ចល័តហ្នឹងអត់សូវដែលហ៊ានមិនដឹងមួយ ណាទេ ខ្ញុំអត់ស្គាល់ឈ្មោះគេទេ ។

វណ្ណៈ អញ្ចឹងគណៈភូមិភាគពីណាគេ តារស់ ញឹម?

ម៉ៅៈ តាញឹម ។

វណ្ណៈ តើពូអាចស្គាល់ តាញឹម ដឹងរឿងរ៉ាវ តាញឹម យ៉ាងម៉េចខ្លះទេ ពូអាចជួយរៀបរាប់បានទេ?

ម៉ៅៈ	គាញឹម គាត់អ្នកភូមិរោគហ្នឹង ។

វណ្ណៈ	គាត់អ្នកភូមិរោគហ្នឹងដែរ?

ម៉ៅៈ	បាទ!

វណ្ណៈ	ហើយម៉េចទៅ ពូអាចស្គាល់គាត់យ៉ាងម៉េច?

ម៉ៅៈ	មនុស្សគាត់ ប្រវត្តិគាត់បើនិយាយទៅខូចខិលតាំងពីដើមមក ក្រោយមកដើររៀបចំហ្នឹងមក ពូថាគាត់មកគាត់មានបងប្អូននៅនេះច្រើន ប៉ុន្តែមិនមែនជាប់សាច់ញាតិខ្ញុំទេ ក៏ប៉ុន្តែខ្ញុំស្គាល់ដែរតើ ញឹម ហ្នឹង ប៉ុន្តែដូចថាស្គាល់យើងមិនសូវហ៊ាននិយាយស្តីជាមួយគេណា៎ គាត់ចុះហៅទៅរៀនសូត្រ ហើយកាលពីសម័យគាត់ហ្នឹងស្រួលទេ មិនសូវជាពិបាកទេ គាញឹម ។

វណ្ណៈ	មិនសូវជាមិនទាន់មានសម្លាប់?

ម៉ៅៈ	បាទ! អត់មានសម្លាប់គ្នាទេ រៀបចំចល័តមូលដ្ឋានអ្នកណាបានប្រើអាវុធគេដាក់នៅការដ្ឋានគោពជ្រហ្នឹង ស្រាប់ចល័តមានគ្រួសារ ដល់ក្រោយមកពេលមកវល់វ៉ុយ៉ាងម៉េចហ្នឹង ទៅបានពួកនារតីមក បានពេលហ្នឹងចប់ហើយខ្ញុំឈប់ហើយ ពេលហ្នឹងខ្ញុំឈប់ពីកាន់ស្អីទាំង អស់ហ្នឹង គេឲ្យមកនៅធ្វើចំការល្ខោល មើលអ្នកចល័តស្គម១ គ្នាប្រហែលជា១០០នាក់ដែរ សុទ្ធតែអ្នកបាក់កម្លាំង ធ្វើការពលកម្មមិនកើតទៅឲ្យមកនៅរើសស្មៅចំការ ឲ្យខ្ញុំមកនៅមើល ប៉ុណ្ណោះឯង ដល់ពេលវៀតណាមចូលមកគេមកតាមឲ្យខ្ញុំរត់ចូលទៅតាមគេ តែខ្ញុំអត់រត់ទេ បើខ្ញុំរត់នៅប្រពន្ធខ្ញុំ កាលហ្នឹងខ្ញុំបានប្រពន្ធហើយ ហើយខ្ញុំនាំប្រពន្ធខ្ញុំរត់ចេញមកនេះមក មកដល់នេះគេតាមខ្ញុំទៀត ខ្ញុំកាលហ្នឹងបិះមិនរួចខ្លួន ខ្ញុំរឹងអត់ទៅជាមួយគេ បើគេឃើញខ្ញុំនេះក៏គេបាញ់ខ្ញុំចោលដែរព្រោះខ្ញុំអត់ទៅ ឲ្យតែចល័តគេតាមគ្រប់គ្នាហ្នឹងឲ្យកាន់កាំភ្លើងនៅត្រពាំងថ្ម ។

វណ្ណៈ	ពួកណាបាញ់?

ម៉ៅៈ	អ្នកដែលមកតាមហ្នឹង ឲ្យតែឃើញគេសម្លាប់ខ្ញុំចោលហើយពួកនារតី ពួកដែលត្រូវរត់ហ្នឹងមិនថានារតីឬពាយ័ព្យទេ ពេលនោះប្រធានកង ប្រធានក្រុមគេតាមភូមិត្រូវតែទៅតាមទាំងអស់ ។

វណ្ណៈ	ឆ្នាំណាពូកាលហ្នឹង?

ម៉ៅៈ	ឆ្នាំប៉ុន្មានដែលវៀតណាមចូល?

វណ្ណៈ	ឆ្នាំ៧៩ ។

ម៉ៅ:	បាទ! ហ្នឹងហើយឆ្នាំ៧៩ ។

វណ្ណៈ	វៀតណាមចូលម៉េចបានមានពីណាតាមបាញ់?

ម៉ៅ:	ពេលនោះវៀតណាមចូលមក ពួកកម្លាំងពួកក្រុមខ្មែរក្រហមទាំងមេភូមិមេក្រុមគេសុទរត់ចូលព្រៃ ម្លោះហើយដូចថាខ្ញុំចល័តអញ្ចេះ អញ្ចឹងគេត្រូវតាមឲ្យទៅជាមួយគេ ។

វណ្ណៈ	អាហ្នឹងបើយើងអត់ទៅ?

ម៉ៅ:	យើងអត់ទៅ បើយើងអត់ទៅភាគច្រើនគេដឹងតែសម្លាប់ចោល ។

វណ្ណៈ	ដល់ពេលស្រួលបួលទៅ បានពូចុះមកនៅភូមិឃុំធម្មតាជាមួយអ្នកស្រុកអ្នកភូមិទៅ?

ម៉ៅ:	ដល់ពេលវៀតណាមចូលមករៀបចំ ខ្ញុំកាលនោះចៅ សុផុន សព្វថ្ងៃគាត់នៅនាយករដ្ឋមន្ត្រីនៅខេត្តតាកែវហ្នឹងឯង កាលហ្នឹងគាត់នៅធ្វើជំនាញការនៅនេះ ពេលវៀតណាមចូលមករៀបចំបានឲ្យកាំភ្លើងខ្ញុំមួយដើម បានប្រកបធ្វើឈ្លប ។

វណ្ណៈ	អាហ្នឹងក្រោយ៧៩ទេ?

ម៉ៅ:	បាទ! ដល់ក្រោយ៧៩មកបានខ្ញុំមានកាំភ្លើង ហើយបានខ្ញុំហ៊ានមកផ្ទះ ។

វណ្ណៈ	ចុះពូខ្ញុំចង់សួរទាក់ទងទៅការដែលពូថា តាញឹម ស្គាល់សោ ភឹម អីយ៉ាងម៉េចពូធ្លាប់ស្គាល់ ដែរសោ ភឹម?

ម៉ៅ:	ខ្ញុំមិនស្គាល់តាសោ ភឹម ទេ បើ តាញឹម ខ្ញុំស្គាល់ ។

វណ្ណៈ	ចុះកូនចៅ តាញឹម ពូស្គាល់អ្នកណាខ្លះ?

ម៉ៅ:	ខ្ញុំអត់ស្គាល់ទេកូនចៅ តាញឹម គាត់អត់មានបងប្អូនទេនៅនេះឲ្យមេភូមិ តាគិល ហ្នឹងមានបងប្អូនគេ ។

វណ្ណៈ	ពីណា?

ម៉ៅ:	តាគិល នៅភូមិខាងជើងមានបងប្អូន ។

វណ្ណៈ	តាគិល ហ្នឹងមានតួនាទីអីដែរ?

ម៉ៅ:	គាត់ប្រជាជន កាលពីដើមគាត់ធ្វើមេកងនៅភូមិនេះឯង តែបងប្អូន តាញឹម អាចស្គាល់ប្រវត្តិតាញឹម ។

វណ្ណៈ	អញ្ចឹងពូគិតថា កាលហ្នឹង តាញឹម ខូចខិលដែរ ក្បត់ឬក៏យ៉ាងម៉េច?

ម៉ៅ:	គាត់ខូចខិលក្បត់ដែរ គាត់ប្រុងក្បត់ដែរ តែនារតីធ្វើបានមុន បើតាមខ្ញុំដឹងឲ្យតែពួកចល័តគាត់ចល័តតំបន់នោះប្រុង ធ្វើអាងហើយនឹងប្រុងពាក់កាំភ្លើងចូលព្រៃហ្នឹងអាហ្នឹងតាមដែល ខ្ញុំដឹងណា៎ ។

វណ្ណៈ　　កូន តាញឹម ឈ្មោះអីគេ?

ម៉ៅៈ　　ឈ្មោះ ជៀល តែមិនដឹងស្អី ជៀល ទេ ។

វណ្ណៈ　　ជៀល ហ្នឹងមានតួនាទីអីដែរ?

ម៉ៅៈ　　មិនដឹងជាតួនាទីស្អីទេខ្ញុំអត់ដឹងទេ តែខ្ញុំឮគេហៅ អាជៀលៗ ហ្នឹងបើតាមដឹងដូចជាត្រូវបាននឹងកូនស្រីតាសោ ភឹម ឈ្មោះ អាជៀល ហ្នឹង ។

វណ្ណៈ　　ប៉ុន្តែ ជៀល ហ្នឹងក្រោយមកគេចាប់គាត់បាត់ហើយមែនទេ?

ម៉ៅៈ　　ចាប់ទាំងអស់គ្នា ទាំងកូនស្រីសោ ភឹម ចាប់តាសោ ភឹម តាញឹម ដោយសារម៉ៅខ្សែជាមួយគ្នាជាជន្ទងជាមួយគ្នាហ្នឹងឯងបានចាប់មួយខ្សែ មិនដឹងគេនោះគេគម្រោងក្បត់ម៉េចបើតាមខ្ញុំដឹងគេប្រុងក្បត់ដែរ ម្នាក់ពីនាក់ខ្ញុំប្រុងគេចភូមិភាគ ខាងនោះប្រុងធ្វើដែរ បើតាមខ្ញុំដឹងមិនដឹងមានអត់ ប៉ុន្តែដូចថាមនុស្សវាជុំដូចថាប្រាប់ពីហេតុផល ។

វណ្ណៈ　　ចុះពូដូចថាខ្ញុំចង់ដឹង ពូនិយាយប្រវត្តិដូចថា ពូកាន់មនុស្ស៣០០នាក់ហ្នឹងប្រជាជនយើងហ្នឹង?

ម៉ៅៈ　　ប្រជាជន ។

វណ្ណៈ　　ប្រជាជនហ្នឹងគឺដឹកនាំធ្វើការយ៉ាងម៉េចខ្លះពូ?

ម៉ៅៈ　　មានអី មានតែឲ្យទៅវែកដីហ្នឹងឯង ។

វណ្ណៈ　　វែកដីនៅណាខ្លះទៅ?

ម៉ៅៈ　　វែកធ្វើទំនប់ត្រពាំងថ្ម ធ្វើទំនប់ភូមិរោគ សុទ្ធតែ៤ម៉ែត្រគីបទៅ៥ម៉ែត្រគីបអ្នកដែលកម្លាំងធ្វើមិនហើយអត់បាយទៅ ។

វណ្ណៈ　　តាមខ្លះខ្ញុំជួបគេថាក្នុងម្នាក់ តែ៣ម៉ែត្រគីបទេ?

ម៉ៅៈ　　តាមកម្លាំងទី១ ទី២ មាន២ម៉ែត្រគីបសម្រាប់អ្នកដែលបាក់បៀវ បើយើងសព្វថ្ងៃយើងធ្វើការកើតគេឲ្យ២គីប បន្ទាប់មក៣ម៉ែត្រ កម្លាំងទីមួយ៤ម៉ែត្រ បើសម្រាប់អ្នកដែលខុស៦ម៉ែត្រគីប ។

វណ្ណៈ　　អ្នកខុស?

ម៉ៅៈ　　បាទ!

វណ្ណៈ　　ចុះបើធ្វើមិនហើយ?

ម៉ៅៈ　　បើធ្វើមិនហើយយូគេថែមហើយធ្វើទារុណកម្មយើង មិនគិតថាពីណាពីណីទេ ។

វណ្ណៈ អញ្ចឹងបើសិនជាអ្នកហ្នឹង៦ម៉ែត្រគឺបច្បាស់ជាអត់ហើយ ហើយបើថែមទៀតច្បាស់ជាអត់ហើយ អញ្ចឹងទីបញ្ចប់ប្រហែលជាមិនអាចរស់ទេ?

ម៉ៅៈ ពិបាកនឹងរស់ណាស់ មានអ្នកលបជួយលបអី ជួនកាលទៅស៊ីសងលើអ្នកគ្រប់គ្រងទេ ដូចក្តាប់វះក្តាប់កងធំអាចអនុគ្រោះឲ្យ មិនបានទេណា៎លោកគ្រូ គ្រាន់តែខុសនៅទំនប់ត្រពាំងថ្មហ្នឹងភូមិចម្ងាយប្រហែលជា២០ម៉ែត្រហ្នឹងមិនអាចទៅជ្រកម្លប់ហ្នឹងបានទេ សុទ្ធតែពួកសេនាជន ពួកយោធាគេយាម កាលណាគេចាប់យើងបានយើងហ្នឹង៦ម៉ែត្រគឺបផ្លូវហើយ ដឹកតែទឹក គ្រាន់តែមនុស្សល្ងិតមាន់ឲ្យវែកដឹកដៃគ្នាបើតាមមើលទៅគួរឲ្យវេទនាណាស់ ចាប់កាន់ ឲ្យវែកតគ្នា ហើយទំនប់ហ្នឹងខ្ពស់ណាស់ពីដើម ៥ទៅ៦ម៉ែត្រ វែកឡើង ហើយបើនិយាយពី រុយវិញដូចទឹកប្រហុកអញ្ចឹង ល្មមៗគេដាក់ត្រីឆ្អៅឲ្យវាស៊ីទៅក្រោយមកទឹកប្រហុកសុទ្ធ រុយឡើងវិល ម៉ាទោសចុះមិនបាច់នេះទេ គ្រាន់តែទឹកប្រហុកបើកដួសឲ្យយើងវាធ្លាក់មិនដឹង ប៉ុន្មានទេ ហើយគ្រាន់តែមនុស្សបត់ជើង បើខ្ញុំគិតទៅដើរដីមួយគីឡូអត់ទាន់ដុតទេ មិនមែន រយពាន់នាក់ទេគ្រាន់តែអ្នកទៅបត់ជើងឈរទៅវាមិនមែនស្រួលណា៎ ។

វណ្ណៈ មនុស្សប្រហែលជាច្រើនរាប់ម៉ឺនរាប់ពាន់នាក់?

ម៉ៅៈ ច្រើនរាប់ម៉ឺន ហើយខ្ញុំទៅដល់មុនដំបូងគេឲ្យតំរង់ទំនប់ គេដាក់បើសិនជាតំរង់ខ្ញុំខាងនេះក៏តំរង់ ហើយខាងនោះក៏តំរង់ បើសិនជាអ្នកតំរង់នោះខុសគ្នាវិញគេវៃយើងចោលហើយ ហើយឈើសុទ្ធតែកំពស់ណាណី ឲ្យតំរង់ គេខាងនោះក៏លើក គេថាធ្វើម៉េចឲ្យតែទំនប់ខុសគ្នាគឺអ្នកតំរង់ហ្នឹងស្លាប់ហើយ ខ្ញុំភ័យដែរ ។

វណ្ណៈ ចុះពូ ឧបមាថាពូទៅអាងត្រពាំងថ្ម ពូទៅតាំងពីឆ្នាំណា?

ម៉ៅៈ ឆ្នាំប៉ុន្មានទេលោកគ្រូ រំដោះបានតែមួយឆ្នាំទេទៅធ្វើអាងត្រពាំងថ្ម ។

វណ្ណៈ អញ្ចឹង៧៦?

ម៉ៅៈ ៧៦ហ្នឹងធ្វើហើយ ។

វណ្ណៈ ៧៦ហ្នឹងពូទៅហ្មង?

ម៉ៅៈ បាទ! កាលហ្នឹងដើរពីនេះទៅអាងត្រពាំងថ្ម ដើរដូចឆ្ងាយមែនទែន ចល័តចេញទៅហ្នឹងគ្នាច្រើន ។

វណ្ណៈ អញ្ចឹងពូ គ្នារបស់ពូមិនលើសពី៣០០នាក់ហ្នឹងទេ ហើយអញ្ចឹងដូចថាពូកាន់៣០០នាក់មាន អ្នកផ្សេងកាន់៣០០នាក់ ហើយមានអ្នកផ្សេងកាន់បន្តៗគ្នាច្រើនទៀតរាប់ម៉ឺននាក់ទៅ

ប៉ុន្តែពូទទួលខុសត្រូវតែប៉ុន្មាននរយនាក់ហ្នឹង ចុះអ្នកវាស់អ្នកវែងអ្នកណាអ្នកវាស់អ្នកអីហ្នឹង ពូអ្នកវាស់ឲ្យដែរឬក៏មានអ្នកវាស់ផ្សេង?

ម៉ៅៈ គេវាស់ឲ្យរែកគេមានកងមេក្រុមគេ ខ្ញុំដូចថាកាលហ្នឹងគេឲ្យវាស់តំរង់តែទំនប់ហើយឲ្យគេលើក ហើយអារឿងវាស់ចាត់ចែងហ្នឹងកម្មករគេ ។

វណ្ណៈ អញ្ចឹងពូមើលការខុសត្រូវចំពោះអ្នកដែល ប្រជាជនដែលរែកហ្នឹង ហើយពូអ្នកតំរង់ទេ មិនមែនអ្នករែកទេ?

ម៉ៅៈ ពេលតំរង់ជួយរែក ។

វណ្ណៈ ជួយរែកខ្លះដែរ?

ម៉ៅៈ បាទ! ជួយរែកគ្នា មិនអាចឲ្យយើងទំនេរបានទេ វាមិនឲ្យយើងទំនេរទេ ។

វណ្ណៈ ចុះពូ បើតាមពូសង្កេតឃើញ ពេលពូនៅប៉ុន្មានឆ្នាំនៅហ្នឹង?

ម៉ៅៈ ទំនប់ហ្នឹងប្រហែលជាជិតមួយឆ្នាំព្រោះយូដែរ ។

វណ្ណៈ ប្រហែលមួយឆ្នាំ?

ម៉ៅៈ បាទ! គេឲ្យចូលឆ្នាំនៅហ្នឹង ។

វណ្ណៈ ពូនៅទាល់តែហើយ?

ម៉ៅៈ បាទ! នៅទាល់តែហើយ ។

វណ្ណៈ ទាល់តែហើយទំនប់ហ្នឹង?

ម៉ៅៈ បាទ! ហើយអាត្រង់បត់កែងទៅស្ពានទី១ ចាក់ចម្ងាយជាងគេប្រហែលជា១០០ម៉ែត្រ ប្រមូលចល័តទាំងអស់ ទៅចាក់ហើយទៅរកចិនទៀតណា៎ ចិនធ្វើជាងគេទៀតណា៎ ។

វណ្ណៈ កាលហ្នឹងមានចិនមានអីដែរ?

ម៉ៅៈ មាន ។

វណ្ណៈ មានជនជាតិចិនទៅដែរ?

ម៉ៅៈ មាន វាទៅមើលរហូតដល់ដើររកវែស្បូងវត្ថុធាតុដើម ជាតិថ្ម ស៊ីម៉ង់ត៍ស្អី មាន!ចិន ។

វណ្ណៈ អញ្ចឹងមានត្រាក់ទ័រ មានអាម៉ាស៊ីនរុញបង្ហាប់ដីទេ?

ម៉ៅៈ មានអាជាន់បង្ហាប់ មានតែអាឡូ ។

វណ្ណៈ មានឡានអាឡូ?

ម៉ៅៈ មាន អគ្គីសនីយើងមាន វាដល់ដើមពោធិ៍នៅចំពីលើរំដួលអីអាចលើកចំទំនប់ ដើមពោធិ៍ធំៗណាស់ដល់រំដួល ។

វណ្ណៈ អញ្ចឹងមានអាឡូរុញដីដែរ?

ម៉ៅៈ មានអាឡូចិន មិនដឹងគេយកពីណាទៅទេដាក់ឲ្យចិនយើងចាក់បង្គីរទៅគេជាន់ ។

វណ្ណៈ អញ្ចឹងចិនជាអ្នកបច្ចេកទេសនៅហ្នឹង?

ម៉ៅៈ បាទ!

វណ្ណៈ ហើយយើងវែកដីទៅ?

ម៉ៅៈ បាទ! យើងវែកដី ។

វណ្ណៈ ហើយគេរុញ?

ម៉ៅៈ បាទ! គេអ្នករុញ ចិនហ្នឹង ។

វណ្ណៈ ចុះពូ អ្នក១៧មេសាដែលជម្លៀសមកពីភ្នំពេញត្រូវគេប្រមូលទៅហ្នឹងទាំងអស់?

ម៉ៅៈ ទៅជុំគ្នាទាំងអស់ មិនគិតថាអ្នកពីណាទេ ។

វណ្ណៈ មិនគិតអ្នកថ្មីអ្នកចាស់ ។

ម៉ៅៈ មិនគិតគេ តែទាំងអស់គ្នាហ្នឹង ។

វណ្ណៈ តើពូសង្កេតឃើញទេថា យើងកំពុងធ្វើការអញ្ចឹងមានអ្នកខ្ជិលច្រអូសអញ្ចឹងត្រូវគេចាប់ចង យកទៅបាត់អញ្ចឹងមានទេ?

ម៉ៅៈ គេហៅទៅ តែមិនដឹងយកទៅណា ថាយកទៅរៀនៗគេឲ្យទៅរៀនតែមិនដឹងទៅណា ស្រាប់ តែមិនដែលឃើញមកវិញ ។

វណ្ណៈ អញ្ចឹងមានស្លាប់ច្រើនទេនៅអាងត្រពាំងថ្មហ្នឹង?

ម៉ៅៈ ច្រើន បើតាមខ្ញុំដឹងច្រើនណាស់ ប៉ុន្តែដូចថាគេហៅទៅរៀនហ្នឹងវាបាត់ខ្លួន ។

វណ្ណៈ ចុះកងពូមានក្រុមណាផ្សេងមកចាប់ទេ នៅក្រុមពូ៣០០នាក់ហ្នឹង?

ម៉ៅៈ អត់មានទេ កងរបស់ខ្ញុំមិនដែលមានបញ្ហាអីទេ មិនដែលមានអ្នកណាចាប់ចងទេ មានតែ ស្អុមស្គាំងរត់ទៅ ដូចថាខ្ញុំស្គាល់ យាយថែម ដោយសារពួកកូនចៅគាត់ចាប់បានចាប់ដាក់ សន្តិសុខដាក់ខ្នោះគេទុកទៅ ដល់ពេលខ្ញុំដឹងទៅខ្ញុំទៅសុំគាត់យកទៅ ។

វណ្ណៈ អញ្ចឹងឥឡូវយើងនិយាយជិនាន់ តាវ៉ាល់ សិន តាម៉ោង តាក្រុក តាអីហ្នឹងយើងនិយាយ ពេលហ្នឹងសិន ព្រោះពេលហ្នឹងពួកគាត់ហ្នឹង តាវ៉ាល់ ហ្នឹងនៅគ្រប់គ្រងនៅអាងត្រពាំងថ្មហ្នឹង ដែរ មុន យាយថែម ទៀត?

ម៉ៅៈ មុន! ។

វណ្ណៈ អញ្ចឹងពូ ចង់និយាយពីសកម្មភាពហ្នឹងមើល តើ តាវ៉ាល់ តាម៉ោង ហ្នឹងគាត់ដាក់បទបញ្ជា មកដូចថាពីលើមករហូតដល់ពូ ហើយពូដាក់ទៅក្រោមទៀតយ៉ាងម៉េចដែរ ខ្ញុំចង់ដឹងរចនាសម្ព័ន្ធ?

ម៉ៅៈ រឿងគេមិនដឹងទទួលម៉េចទេពីខាងលើ តែមកដល់កំណត់ឲ្យពួកខ្ញុំដូចខ្ញុំថាអញ្ចឹង ពួកខ្ញុំមើលទៅសាច់ប្រឡូករាងធំៗដឹងតែ៨ម៉ែត្រគីប មិនគិតថាយើងធ្វើរួចឬក៏មិនរួចទេ ហើយក្រោយមកដូចថាអ្នកណារាងស្គមស្គាំងអញ្ចឹង៣ម៉ែត្រគីប ២ម៉ែត្រគីប សូម្បីតែអ្នកខ្វាក់មាន់ក៏មិនឲ្យសល់លោកគ្រូឯងគិតមើល ។

វណ្ណៈ អាហ្នឹងខ្វាក់មាន់ដោយសារមូលហេតុអី?

ម៉ៅៈ ចុះក្តៅ នៅទំនប់ត្រពាំងថ្មនេះមួយអាទិត្យបានមុជទឹកម្តង ។

វណ្ណៈ អត់មានទឹកទៀត?

ម៉ៅៈ អត់មានទេ បើគេជីកអណ្តូងបើគិតទៅវាច្រើនរណ្តៅដែរ តែអ្នកនៅវាល់ទឹកចែកគ្នាអ្នកហ្នឹងនៅតែរហូត ។

វណ្ណៈ អញ្ចឹងខ្វះបាយហើយទឹកទៀត?

ម៉ៅៈ ខ្វះទាំងទឹក មានតែទឹកស្រះ ។

វណ្ណៈ ហើយបាយគេឲ្យញ៉ាំប៉ុន្មានដែរកាលហ្នឹង?

ម៉ៅៈ បាយមាន ដូចថារបបមានម្នាក់មួយកំប៉ុងកន្ទះ ។

វណ្ណៈ មួយកំប៉ុងកន្ទះយើងហូបម៉េចអស់ ច្រើនណាស់?

ម៉ៅៈ មួយកំប៉ុងកន្ទះ ទាំងអស់គ្នានេះគិតមួយកំប៉ុងកន្ទះតែអត់មានឲ្យយើងស៊ីទេ ក្រោយមកគេកាត់បន្ថយ មុនដំបូងមួយកំប៉ុងកន្ទះក្រោយមកម្នាក់មួយកំប៉ុងទេ ។

វណ្ណៈ ហើយក្រោយមកគេកាត់បន្ថែមទៀត?

ម៉ៅៈ គេកាត់បន្ថែមទៀត ។

វណ្ណៈ នៅសល់មួយចានអញ្ចឹងទៅ?

ម៉ៅៈ បាទ! នៅសល់មួយចាន ។

វណ្ណៈ មួយចានចង្អឹះ?

ម៉ៅៈ បាទ! ប៉ុន្តែបើថាឲ្យស៊ីឲ្យឆ្អាញ់ ដូចថាពួកខ្ញុំធ្វើការហ្នឹង៤ម៉ែត្រគីបហ្នឹងលៃយ៉ាងម៉េចឲ្យបានហើយប៉ុណ្ណេះៗមក ហើយមកទៅជីកកណ្តុរជីកក្តាមម៉េចអាចបាន រកទុកពេលល្ងាចយើងស៊ី ។

វណ្ណៈ ប៉ុន្តែយើងសំខាន់បើថាខ្វះអាហារហើយ ប៉ុន្តែផ្នែកទឹកនេះ ខ្វះទឹក?

ម៉ៅៈ ខ្វះមែនទែន លោកគ្រូបើនិយាយពីរឿងទឹកមួយស្រះ ទឹកស្រះត្រពាំងថ្មមួយគេមិនឲ្យមុជផង ហើយដឹកមិនបានមួយអាទិត្យទេណា៎ អត់បានមួយអាទិត្យទេស្រះក្បែត្រពាំងថ្មត្រូវតែរីង ។ ក្រោយមកដីលើគោកពត្រមានបឹងមួយ មានប្រាសាទមួយ បើគិតទៅ៣ថ្ងៃទេ ត្រឹមតែ៣ថ្ងៃទេ អត់ឲ្យមុជទាំងអស់ អ្នកណាមុជចាប់បានសុទ្ធតែ៦ម៉ែត្រគឺបរហូតដល់គេវ៉ៃចោលក៏មាន គេគំរាមមិនបាន ទៅដល់ដឹងតែពេលដែលចុងបញ្ចប់គេបបរស្ករឲ្យស៊ីរឹកដូចកំពង បើនិយាយពីរឿងទឹកខ្វត់មែនទែន ទឹកគ្រាន់តែដើរមកផ្ទូតជិតដល់តាវ៉ូង គ្រាន់តែដើរទៅនឹងមកវាមិនបាច់មកផ្ទូតក៏បានដែរ ដើរមកអញ្ចេះក៏ផ្ទូត ដើរមកវិញ វាអត់មានអាពេលដើរមកផ្ទូតដល់ វាធ្វើការមិនហើយដើរ៣-៤-៥ម៉ោងបានដល់ ពិបាកមែនទែន ។

វណ្ណៈ ចុះពេលព្រលឹមឡើង ស្មានម៉ានគេឲ្យចុះធ្វើការ?

ម៉ៅៈ គ្មានទេលោកគ្រូ ចាប់ពីម៉ោង១ ម៉ោង២ ម៉ោង៣យប់ អត់មានចាំថ្ងៃភ្លឺរះទេ ។

វណ្ណៈ ចុះត្រូវមានពេលសម្រាកដេកយប់ដេកអីដែរ?

ម៉ៅៈ ដេកបានតែមួយភ្លែត ជួនកាលមិនបានដេកផង ចាប់ធ្វើមើលតែថាធ្វើមិនរួចចាប់ធ្វើតាំងពីល្ងាច ។

វណ្ណៈ ចុះមានអញ្ចេះទេ ដូចថាអ្នកខ្វះអញ្ចឹងគេដាក់ថា៣ម៉ែត្រគឺបអញ្ចឹង ប៉ុន្តែធ្វើអត់ហើយ ដល់ពេលមួយថ្ងៃធ្វើអត់ហើយអញ្ចឹង យប់ឆ្មៀតមកធ្វើទៀតដើម្បីស្អែកទទួលដែនការថ្មី?

ម៉ៅៈ មាន ។

វណ្ណៈ បើសិនជាយើងមិនធ្វើទេ ស្អែកគេបន្ថែមថ្មីទៀត?

ម៉ៅៈ បាទ! គេត្រួត យើងសល់ប៉ុន្មានគេត្រួតថែម ។

វណ្ណៈ ហើយយើងកាន់តែអត់ហើយ អញ្ចឹងវាទៅជាបញ្ហា ដូចថាអង្គការគេយកទោសយកពៃយើង?

ម៉ៅៈ បាទ! យើងមិនបាច់ថាអ្នកណាប្រើអ្នកណាទេលោកគ្រូ ដូចលោកគ្រូសួរថា ពេលម៉ោងប៉ុន្មានព្រឹកបានទៅធ្វើការ គ្មានទេ ពេលនោះឯងខ្លាចនៅពេលនោះឯងបានប្រឹងធ្វើ ម៉ោង១២យប់ក៏ប្រឹងធ្វើ រហូតដល់ព្រឹកម៉ោង១១ដល់ល្ងាច ប៉ុន្តែដូចថាវារែកពល់ថ្ងៃទៅដូចថាវាសុាំដឹងក្បួនកាប់ដី កាប់តែត្រពីត្រពាសដូចអត់លឿនដែរ ទៅដល់គេវាស់ឲ្យ២ម៉ែត្រទៅដល់ដាក់បង្គីរពិបកាប់ប្រឡោះក្រឡាប៉ុណ្ណេះ មើលទៅដូចតូច តាមពិតទើបចូលបាន៧-៨

កិច្ចហើយផ្ទៃដាក់អានេះម៉ាកិច្ចៗទៅ ហើយសុទ្ធតែរាប់បង្គីរពេលគេយកទៅឲ្យគេសុទ្ធតែរាប់៣០អំរែកម៉ាគីប ទាបបំផុតអត់ឲ្យដល់៣៥អំរែកទេ សុទ្ធតែអ្នកដឹងចំនួន ។

វណ្ណៈ អញ្ចឹងមួយថ្ងៃដឹងតែ១០០អំរែក?

ម៉ោះ បាទ! គេដឹងចំនួន ដល់ពេលធ្វើរែកឡើង កាលហ្នឹងមានបារីបើកឲ្យដែរ ឡើងៗដាក់បង្គីរ ដាក់មួយជាប់ ឡើងៗលួចក្អាល់គ្នាលេងទៅ ដល់ជំហានទៀតលើខ្នងចក្រឡើងអត់រួចអុកគូទ ទឹះ ចាញ់គ្នាអស់បារីកន្លះកញ្ចប់ ។

វណ្ណៈ អាហ្នឹងឆ្នាដំបូងៗទេ?

ម៉ោះ បាទ!

វណ្ណៈ ដល់ពេលឆ្នាំក្រោយៗមកយើងមិនអាចមានបារីមានអីទេ?

ម៉ោះ អត់មានទេ អត់មានបារីទេ ។

វណ្ណៈ តឹងទៅៗ?

ម៉ោះ បាទ! តឹងទៅៗរហូត ។

វណ្ណៈ អញ្ចឹងដើងទំនប់ ម៉េញពូថាកំពស់៦-៧ម៉ែត្រ?

ម៉ោះ បាទ!

វណ្ណៈ ហើយចុះទទឹងអាចបើកឡានបានទេ?

ម៉ោះ ទទឹង៦ម៉ែត្រកាលពីដើម ។

វណ្ណៈ ហើយបណ្តោយប្រហែលប៉ុន្មានគីឡូដែរ បណ្តោយទំនប់ម៉ាព័ទ្ធអាងហ្នឹង?

ម៉ោះ ឆ្អែលពីត្រពាំងថ្មមិនទៅចេះខាងលើ ពីអញ្ចឹងឆ្អែលទៅដល់ភូមិទៅដើងទៀត ប្រហែលជា ១០គីឡូជាងដីហ្នឹង ប៉ុន្តែជ្រៅតែកន្លែងត្រពាំងថ្មហ្នឹងឯង សព្វថ្ងៃដូចជាទាប សព្វថ្ងៃដូចមាន តែ៦-៧ម៉ែត្រទេទំហំ ។

វណ្ណៈ ចុះគេថាអញ្ចេះ
គេថាជួនកាលគេសម្លាប់មនុស្សមួយចំនួនដាក់នៅដើងអាងត្រពាំងថ្មហ្នឹងដែរ
អាហ្នឹងមានទេ?

ម៉ោះ អត់មានទេ បើនិយាយអារឿងថាធ្វើឲ្យយើងឃើញអត់មានទេ មានតែទៅរៀន តែមិនដឹង ទៅរៀននៅណាបាត់ បើថាធ្វើឲ្យយើងឃើញអត់មានទេ ខ្ញុំសង្កេតទៅអត់មានធ្វើឲ្យឃើញ ទេ បើចាប់ឲ្យឃើញ ឧទាហរណ៍ថា បើត្រូវចាប់អត់មានឃើញទេ ហើយបើវៃដួលផ្កាប់មុខ ក៏អត់មានដែរ ។

វណ្ណៈ	ចុះពូ ពូមានឃើញចាប់ពីណាខ្លះកាលសម័យហ្នឹង?

ម៉ៅៈ	បើចាប់គឺចាប់តែពួកគេថ្មីៗហ្នឹង ខ្ញុំមិនដែលស្គាល់ទេ កាលនោះអត់មានស្គាល់គ្នាអស់ទេ សូម្បីតែខ្ញុំក៏ខ្ញុំមិនដែលហ៊ានស្គាល់ គ្នាខ្ញុំប៉ុន្មាននាក់ហ្នឹងមិនដែលស្គាល់ឈ្មោះថាស្អីៗ គ្រាន់តែវាស្គាល់ខ្ញុំថាទៅណាក៏ទៅៗ ។

វណ្ណៈ	ចុះពូ ពូឃើញចាប់អ្នកថ្មីអញ្ចឹង?

ម៉ៅៈ	បាទ! កាលជិនាន់យួន គេបំបាត់យួនទៅមានឃើញ ឃើញចាប់ហើយមិនដឹងយកទៅណាទេ ។

វណ្ណៈ	សម័យខ្មែរក្រហមហ្នឹងម៉េចគេថាមានយួន?

ម៉ៅៈ	ជនជាតិយួនមកនៅស្រុកខ្មែរហ្នឹង ឲ្យតែយួនដឹងតែគេចាប់ហើយកាលហ្នឹង យួនគេសម្លាប់ចោល ទាហានក៏ដោយ ឲ្យតែយួនដឹងតែគេចាប់សម្លាប់ចោលទាំងអស់ ក្រោយមកគេចាប់យួនទាំងអស់ ឲ្យតែគេស៊ើបដឹងថាខ្សែយួនគេចាប់ បើមិនដឹងកូនចល័តទេ គេដឹងពីឪពុកម្តាយប្រវត្តិយួនគេចាប់ឪពុកម្តាយហើយគេសួរថាកូនទៅនៅឯណា គេតាមទៅចាប់ទៀត ។

វណ្ណៈ	ចុះពូដូចថា ពេលដែលពូកាន់មនុស្ស៣០០នាក់ហ្នឹង តើពូប៉ុន្មានថ្ងៃពូឡើងជួបគេម្តង?

ម៉ៅៈ	អត់មានទេ ។

វណ្ណៈ	អត់មានទៅជួបគេទេ?

ម៉ៅៈ	គ្មានទេ គេមានមេរោងៗគេនៅនោះ គេមើលយើងធ្វើទៅ គេអត់មានប្រាប់អីផង គេមើលតែយើងដឹងតែទំនប់ក្រោម២ម៉ែត្រ ហើយលើ២ម៉ែត្រ គេដាក់ផែនការឲ្យយើងប៉ុណ្ណឹង ។

វណ្ណៈ	ចុះ តាម៉ោង ហើយនឹង តាវ៉ាល់ ដែលស្តីឲ្យពូទេ?

ម៉ៅៈ	អត់សូវដែលបានជួបគេទេ ព្រោះយើងវរៈក្រោម តែស្តីឲ្យហើយព្រោះពួកហ្នឹងកាចៗណាស់ កាចដាច់ យាយបែម ឆ្ងាយណាស់ ពួអ្នកមកពីនោះនិយាយ គេហៅតែតាចង្កូមមាស ។

វណ្ណៈ	ពីណាគេ?

ម៉ៅៈ	តាវ៉ាល់ និយាយអត់សូវច្បាស់ទេ និយាយនឹងមិនដឹងទៅណាទេ ឆ្លើយតែបាៗ អត់មានឆ្លើយបាទទេ ។

វណ្ណៈ	គាត់អ្នកស្រុកណាដែរ តាវ៉ាល់?

ម៉ៅៈ	គាត់អ្នកមកពីភ្នំពេញហ្នឹងឯង ពួកតាម៉ោង តាវ៉ាល់ អីហ្នឹង ។

វណ្ណៈ បើ តាញឹម គាត់អ្នកស្រុកនេះ?

ម៉ៅៈ តាញឹម អ្នកស្រុកនេះ ។

វណ្ណៈ ចុះឆ្នាំណាដែលខាងនារតីចុះមកចាប់ពួក តាវ៉ាល់ ពួកអីហ្នឹង ពូដឹងទេកាលហ្នឹង?

ម៉ៅៈ មិនដឹងឆ្នាំប៉ុន្មានទេ ប្រហែលជាឆ្នាំ៧៧ ៧៧ហ្នឹងនារតីទើបតែចុះមកទេដាក់តាមសហករណ៍ ៧៧-៧៨ហ្នឹង ៧៨បានខ្លាំង ។

វណ្ណៈ ៧៨បានខ្លាំងហ្នង?

ម៉ៅៈ បាទ! ៧៧នៅកេងៗគ្នាទេ តាមខ្ញុំដឹងនៅចល័ត ។

វណ្ណៈ នៅដើរធ្វើការជាមួយគ្នាទេ?

ម៉ៅៈ បាទ! នៅក្នុងក្រុមជាមួយគ្នាទេ តែទៅវាលដាច់ប៉ែក ព្រោះខ្ញុំឃើញកម្លាំង តាញឹម ដែលខ្ញុំស្គាល់ដើរតែតាមវាលហ្នឹង ឲ្យតែពួកហ្នឹងដាច់ប៉ែកគេចាប់វិប ព្រោះបានខ្ញុំស្គាល់ព្រោះខ្ញុំរួចពីធ្វើការខ្ញុំដឹកអន្ទង់ ហើយគេដើរចាក់អន្ទង់ដែរ ហើយជួបគ្នានិយាយគ្នាទៅ សួរចុះសួរឡើង ហើយខ្ញុំខោអាវក្រណោងក្រណោង ដល់បានជួបនិយាយគ្នាទៅគេមានកាំភ្លើងដាក់តាមខ្លួនចាំចាប់ពួកហ្នឹងដែរ បានថាពួកនេះវាសំឡេះគ្នាដូចថាមិនដឹងក្បត់នឹងគ្នាក៏មិនដឹង ហើយអ្នកណាធ្វើបាក់មុន ដូចនារតីគេចុះមកច្រើនគេធ្វើបានមុន គេចាប់មេៗធំដូច តាញឹម បាន កូនចៅក៏ បានចាប់ពួកអ្នកនោះមកបានក្រោយមកចាប់តៗអ្នកណា ហើយជំនាន់ តាក្រក តាញឹម វារៀបមកស្រុកមកឃុំអីវាចាប់តទៅ ឃុំហើយមករៀបសហករណ៍ភូមិ ចាស់ៗគេចាប់តៗ មិនបានខុសទេ បើតាមខ្ញុំដឹងមិនបានខុសទេ សម្លាប់យួន ចិន កូនអ្នក តូច កូនអ្នកធំ សម្លាប់ឪពុកម្តាយ ហើយគេតាមសួររកកូននៅឯណា សល់ឯណាខ្លះ ហើយចល័តនៅណាខ្លះត្រូវតែគេតាម មិនចាំបាច់ថាខុសទេ ។

វណ្ណៈ ចុះពូពួកនារតីមកកាន់ជំនួសពួក តាវ៉ាល់ តាម៉ោង តាក្រកអីហ្នឹង បន្ទាប់ពី យាយចែម ពូស្គាល់ យាយចែម មកបន្តបន្ទាប់មកពូស្គាល់ឈ្មោះទៀតទេ ដែលកាន់ក្រោយហ្នឹងទៀត?

ម៉ៅៈ អត់មានកាន់ក្រោយទេ យាយចែម កាន់ ដល់មនុស្សគ្រប់គ្រងក្រោយហ្នឹងគឺចប់ត្រឹមគាត់ហ្នឹងហ្នង ។

វណ្ណៈ ប៉ុន្តែបន្ទាប់ពី យាយចែម ទៀត?

ម៉ៅៈ ខ្ញុំអត់ស្គាល់ទេ មិនដឹងអ្នកណា សមាជិកគាត់ មនុស្ស យាយចែម ខ្ញុំអត់ស្គាល់ទេ តែដឹងតែគាត់ពីដើមគាត់ធ្វើចៅហ្វាយស្រុក ។

វណ្ណៈ ចុះពូថាធ្លាប់ទៅផ្ទះ យាយថែម?

ម៉ៅៈ ទៅ តែទៅហ្នឹងមិនដែលហ៊ានសួរនាំគេទេ មិនដឹងអ្នកណាវង់អ្នកណាអីទេ ឃើញតែគាត់នៅតែឯង។

វណ្ណៈ ចុះម៉េញពូថា គេរាយការណ៍ប្រាប់ យាយថែម យ៉ាងម៉េច។?

ម៉ៅៈ ឧទាហរណ៍ថា ដូចពួកចល័ត ដូចពួកខ្ញុំនៅកងចល័តដែលជាអ្នកអុចស្នប់អញ្ចឹងណាំ គេអ្នកដូច ថាស្គាល់អញ្ចឹងទៅគេឡើងប្រជុំ ទៅនិយាយថាអានេះអាក្រក់ អានេះល្អ គេចល័តអីអញ្ចេះ អញ្ចុះ ចាក់ដោតគន្លឹះគាត់និយាយ។ បើតាមខ្ញុំអង្គុយស្ដាប់ ពេទ្យមឿន នោះមនុស្សហ្នឹង ល្អណាស់ ពេទ្យនៅក្ដាប់ពួកខ្ញុំ ហើយដល់ពេលអាមួយគេប្រធានក្ដាប់ចល័តមួយតំបន់ ក្ដាប់ ពេទ្យចល័ត ហើយឈ្មោះ អាស្នា ហ្នឹងវង មកវានិយាយខ្ញុំទៅយកចល័តហ្នឹងវានិយាយថា អានេះចេះ។មួយចុះមួយ គាត់សួរខ្ញុំចល័តខ្ញុំអត់ដឹង ខ្ញុំថាខ្ញុំអត់ដឹងទេការងារខ្ញុំ ទោះបីទៅ យកក៏ខ្ញុំមិនដែលហ៊ាននិយាយទេ សភាពការណ៍គេម៉េច ដល់ពេលនិយាយគាត់និយាយ ងាយស្រួលដែរ គាត់ថា អ៊ើ! បើវាពិបាក វាប្រឆាំងក្បត់ហើយវៃចោលទៅ។

វណ្ណៈ គាត់ថាអញ្ចឹងដែរ?

ម៉ៅៈ បាទ! គាត់ថាវៃចោលទៅ។

វណ្ណៈ បើកុំមានអ្នករាយការណ៍ក៏គាត់អត់ដឹងដែរ?

ម៉ៅៈ គាត់មើលមុំវត្តមុំនេះប្រើគេឲ្យទៅហៅ មកវត្តហើយនិយាយពីរបីម៉ាត់វាអត់ដឹងថាគេចាប់វា វារត់ប្រុយ រត់ប្រុយតាមថ្នល់ទៅវិញ គេចាប់យកមកដល់ដាក់ខ្នោះវា វាប្រាប់ខ្ញុំដែរ ចាំ ប្រាប់ប្ដីប្រាប់ប្អូនខ្ញុំផង គេអត់ទុកទេ ពេលព្រលឹមឡើងគេយកទៅវៃចោល។

វណ្ណៈ ពីណាគេ ហើយឈ្មោះអី?

ម៉ៅៈ ឈ្មោះ មិត្តមឿន មឿន ហ្នឹងស្រី។

វណ្ណៈ ពេទ្យមឿន មែន?

ម៉ៅៈ ឈ្មោះ មឿន។

វណ្ណៈ យកវៃចោលឆ្នាំណាពូ?

ម៉ៅៈ ឆ្នាំ៧៧ហ្នឹង។

វណ្ណៈ ពេលពួកនារតីចូលមកហ្នឹងមែន?

ម៉ៅៈ បាទ!

វណ្ណៈ គាត់ខុសអី?

ម៉ៅៈ មានខុសអី ខ្ញុំមិនដឹងថាមានខុសអីទេ ពេទ្យគេដណ្តើមធំគ្នាគេហ្នឹង អនុនោះប្រុស ហើយស្រី នោះប្រធាន ។

វណ្ណៈ ចុះយាយថែម គាត់នៅណាទៅទីតាំងគាត់?

ម៉ៅៈ នៅភ្នំលាភ ផ្ទះនៅសាលាឃុំចាស់ នៅផ្ទះចិនពីដើម ផ្ទះទាម ។

វណ្ណៈ ភ្នំលាភ?

ម៉ៅៈ បាទ!

វណ្ណៈ ពូធ្លាប់ទៅជួប យាយថែម បានប៉ុន្មានដង?

ម៉ៅៈ ជួបបានពាដងដែរ ហើយខ្ញុំទៅយកចល័តជាប់ខ្នោះ គាត់ឲ្យទៅយកវិញ ឆ្លើយថានៅចល័ត តំបន់ទីនេះទីនោះ គេឲ្យពួកនារតីទៅយកវាប្រើឲ្យខ្ញុំទៅយក ។

វណ្ណៈ ពូទៅជួប យាយថែម ទៅជួបធ្វើអីទៅ?

ម៉ៅៈ គេប្រើឲ្យទៅយកចល័តដែលវារត់មក ស្គមៗធ្វើការមិនកើតវាលួចរត់មក ពួកឈ្លបគាត់ចាប់បានយកមកដាក់ខ្នោះសន្តិសុខគេហ្នឹង គេសួរថានៅចល័តអ្នកនេះអ្នកនោះទៅ ប្រាប់មេគេ មេគេប្រើខ្ញុំឲ្យនាំយកទៅ ។

វណ្ណៈ យកទៅណា?

ម៉ៅៈ យកទៅលែងវិញទៅ?

វណ្ណៈ យកទៅកន្លែងធ្វើការវិញ?

ម៉ៅៈ បាទ!

វណ្ណៈ យកកម្លាំងចល័តទៅការដ្ឋានវិញ?

ម៉ៅៈ បាទ!

វណ្ណៈ ពួកហ្នឹងខុសអីបានគេចាប់ទៅកន្លែង យាយថែម?

ម៉ៅៈ វារត់គេចាប់បាន ឈ្លបការពារគេចាប់បាន វាស្គមមានកម្លាំងណាធ្វើការកើត ។

វណ្ណៈ ពូទៅនិយាយថាម៉េចបានជា យាយថែម ព្រមឲ្យ?

ម៉ៅៈ ទេ! គេប្រាប់តែមេ ដូចថាលោកគ្រូឯងមេអញហ្នឹង មេគេប្រើខ្ញុំឲ្យគ្រាន់តែថា គេនិយាយគ្នារួចហើយ ហើយឲ្យខ្ញុំនាំទៅវិញ ខ្ញុំទៅយកមកវិញទៅ ដាក់គុកបានវេរធ្វើបាបបានស្គមខ្លាំង គេឲ្យយកទៅវិញ ។

វណ្ណៈ	មេហ្នឹងពីណាគេ បាននិយាយទាក់ទងជាមួយ យាយថែម?

ម៉ៅៈ	ឈ្មោះ អាខុន នារតី នឹង តាពាល់ នារតីដែរក្តាប់រូម ចល័តពួកខ្ញុំ ចល័តតំបន់ហ្នឹង។

វណ្ណៈ	ខុន ហ្នឹងស្រីឬប្រុស?

ម៉ៅៈ	ប្រុស។

វណ្ណៈ	ចុះ ពាល់?

ម៉ៅៈ	ប្រុស។

វណ្ណៈ	តាពាល់ ហ្នឹងគាត់កាន់ខាងអី?

ម៉ៅៈ	កាន់ចល័តមួយតំបន់ហ្នឹង ជាមួយ អាខុន ហ្នឹងកាន់មួយតំបន់ហ្នឹងឯង ស្លាប់ហើយព្រោះរត់ចូលព្រៃ ហើយប៉ះវៀតណាមដាក់ឡើងខ្ទេច នៅតែប្រពន្ធសព្វថ្ងៃនេះថានៅម៉ាឡៃ។

វណ្ណៈ	ពីណាគេនៅម៉ាឡៃ?

ម៉ៅៈ	ប្រពន្ធ តាពាល់។

វណ្ណៈ	ចុះ តាពាល់ គាត់ទៅណាហើយ?

ម៉ៅៈ	តាពាល់ ងាប់ហើយ កាលវៀតណាម... នៅជាមួយ អាស្នា ដែលថារាយការណ៍ពេទ្យមឿន ឲ្យ យាយថែម វ៉ៃចោលហ្នឹង ពីរនាក់ហ្នឹង គេត្រូវជាមួយ តាពាល់ ក្តាប់រូម គេត្រូវជាមួយ យាយថែម ដែលថាសម្លាប់ យាយមឿន ស្រីដែលខ្ញុំថាហ្នឹង ដល់ពេលជៀសមិនផុតក៏ត្រូវងាប់ជាមួយ តាពាល់ ហ្នឹង ងាប់ជាមួយគ្នាហ្នឹង ។

វណ្ណៈ	ម៉េចបានពូដឹងថា តាពាល់ ស្លាប់?

ម៉ៅៈ	ពូខ្ញុំគាត់រត់តាមគេ គាត់នៅចល័តជាមួយគ្នា។

វណ្ណៈ	អញ្ចឹង តាពាល់ ហើយនឹង តាខុន តើ តាខុន គាត់នៅរស់ទេ?

ម៉ៅៈ	តាខុន មិនដឹងម៉េចទេ ពួកវៀតណាមចូលយើងមិនត្រូវរត់ ប្រហែលជារស់។

វណ្ណៈ	ចុះនៅហ្នឹង នៅខាងព្រះនេត្រព្រះហ្នឹងថាមាននារីៗមកពីខាងនារតីហ្នឹង ដូចថាកាចដែរ ដូចជាឈ្មោះ ភឿន ឈ្មោះ ខុន ឈ្មោះអីហ្នឹងពូស្គាល់ទេ?

ម៉ៅៈ	ខ្ញុំអត់ស្គាល់ទេ បើនិយាយទៅខ្ញុំមិនសូវដែលស្គាល់ទេ មិនសូវដែលបាននៅជិតគេដែរ ហើយឃើញក៏មិនសូវហ៊ាននិយាយជាមួយគេដែរ យប់ឡើងគេចេញដើរព្រាត អត់ខ្លាចទេ។

វណ្ណៈ	ចុះពូនិយាយថា ពូបានទៅជួប យាយថែម ហ្នឹងហើយបាននិយាយជាមួយ យាយថែម ថានៅខាងកន្លែងពូអត់ឃ្លានអញ្ចឹងត្រូវរាយការណ៍ប្រាប់គាត់ថាយ៉ាងម៉េចដែរ?

ម៉ៅៈ ទេ មេគេអ្នករាយការណ៍ប្រាប់ ព្រោះការងារខាងចែកចាយហ្នឹងមិនមែន យាយចែម អ្នកឡូទេ ខាងខ្ញុំណា៎ តំបន់គេដឹកទៅមានដូចថា នៅម៉ាក្តាប់រួមចល័តតំបន់មានសេដ្ឋកិច្ចតំបន់គេមួយ ហើយខាងខ្ញុំវរៈទៅមានចុងភៅ បើនេះចុងភៅគេអ្នកដាំទៅ មួយថ្ងៃប៉ុន្មានកំប៉ុង ហើយចែកដូចថាក្នុងមួយថ្ងៃគ្នាប៉ុន្មាននាក់ បើអត់ឃ្លាំងគឺមានសេដ្ឋកិច្ចគេមួយសម្រាប់ដឹកជញ្ជូនពីខេត្តពីអី ដឹកយកទៅដាក់នៅណានៅណីស្រេចតែគេទេ គេដឹកយកទៅដាក់កន្លែងគេ គេមានកន្លែងគេ កន្លែងគេរៀបចំ ។

វណ្ណៈ អញ្ចឹងបើសរុបទៅ អ្នកដែលកាន់មុនដូច តាវ៉ាល់ កាន់ ហើយឲ្យពួកនារតីមកកាន់ទៀតហ្នឹង ប្រជាជនឆ្នាំ៧៨ហ្នឹងកាន់តែស្លាប់ច្រើនទៅ ឬក៏មានការថយថយយ៉ាងម៉េចទៅតាមអ្វីដែលពូឃើញ?

ម៉ៅៈ ចាំមើល! ពេលសម័យ តាវ៉ាល់ ច្រើនសម្លាប់អ្នកជម្លៀស ។

វណ្ណៈ អ្នកជម្លៀស?

ម៉ៅៈ បាទ! ស្រាវជ្រាវរកទាហាន អ្នកតូចអ្នកធំ អ្នកធ្វើការធំៗ គេស្រាវជ្រាវរកប្រវត្តិ ។

វណ្ណៈ ចុះជំនាន់ យាយចែម?

ម៉ៅៈ ជំនាន់ យាយចែម ត្រូវការសម្លាប់តាមខ្សែ ទី១សម្លាប់ ឧទាហរណ៍ថាអ្នកខុស ហើយនឹងយួន កាលហ្នឹងជនជាតិយួន ហើយសម្រាប់ថាខ្ញុំដឹងតែខ្ញុំជនជាតិអញ្ចឹងគេដាក់ផ្តាច់ពូជហើយ ហើយឧទាហរណ៍ថា បើចាប់មេឃុំអញ្ចឹង ខ្សែរបស់មេឃុំអាណាជំនិតរបស់មេឃុំ គេស៊ើបដឹងថាប្រធានសហករណ៍ឬក្រុមត្រូវតែស្រាវយក អាហ្នឹងកាលជំនាន់នារតី អាសម្លាប់តគ្នា ។

វណ្ណៈ អញ្ចឹងដូចថា ជំនាន់ យាយចែម ហ្នឹងឲ្យតែថាមេឃុំមានខ្សែរយៈប៉ុន្មានគឺត្រូវចាប់យកមកទាំងអស់?

ម៉ៅៈ បាទ! បើថាមេឃុំហ្នឹងខុសគេស្រាវជ្រាវរកទៀត មិនគិតថាប្រជាជន មិនគិតថាកូនចៅ ឬក៏មេកងអីទេគឺចាប់មួយខ្សែហ្នឹងពួកនារតី ។

វណ្ណៈ ចុះពូនៅអាងត្រពាំងថ្មហ្នឹងដូចថា អ្នកហ្នឹងឈឺគេបញ្ជូនមកពេទ្យនៅហ្នឹងឬក៏មានពេទ្យប្រចាំការនៅណា?

ម៉ៅៈ គេដាក់នៅត្រពាំងថ្មហ្នឹងឯង ។

វណ្ណៈ អញ្ចឹងកន្លែងដេកយ៉ាងម៉េចដែរពូ?

ម៉ោះ	កន្លែងដេកគឺរកកៅស៊ូគ្រប់រៀង១ខ្លួន ។

វណ្ណៈ	គេធ្វើរោងវែងទេ?

ម៉ោះ	អត់មានទេ មានតែកៅស៊ូព័ទ្ធ រកកន្សែងព័ទ្ធហើយដេកទៅ បើមុងមានគេបើកឲ្យ កៅស៊ូអីមានគេបើកឲ្យ បើមុសម៉ែអាមុស រកតែពេលដេកហ្នឹងពិបាកណាស់ អាពេលដេកវាគ្មានផង បើយើងដេកវាមិនរួចហើយត្រូវត្រួតដូចថាហ្នឹងឯងដល់ហើយត្រូវធ្វើទាល់តែឈប់ច្រើងឯង យើងខ្លាចមិនរួចធ្វើម៉ោងណាម៉ោងហ្នឹងម៉ោង១២យប់ធ្វើទៅ ធ្វើដល់ម៉ោងប៉ុន្មានសម្រាក ធ្វើប៉ុណ្ណាធ្វើទៅ ហើយយើងចង់រកស៊ីអាពេលយើងអត់ យើងធ្វើម៉េចខំរក ជួនកាលទៅបានធ្វើតាំងពីម៉ោង១២ម៉ោង១១ហើយ រែកពីព្រឹក២គីបកន្ទះអីទៅ ទុកម៉ាគីបកន្ទះបង្ហើយទៅ ព្រឹកដល់ម៉ោង១១អញ្ចឹងយើងអាចទៅរកក្តាមខ្យងបានស៊ី បើយើងមិនងើបពីយប់ទេដឹងតែអត់មានអីស៊ីទេ ។

វណ្ណៈ	ចុះបើសិនជាយើងងើបរកទៅ ជួបឈ្លបជួបអីទៅ យើងមិនខ្លាចឈ្លប?

ម៉ោះ	ទេ ពេលនោះគេអត់វ៉ៃទេ បើយើងធម្មតាគេអត់ប្រកាន់ទេចល័ត យើងហើយការងារហើយយើងទៅដើកទៅរកចុះ ។

វណ្ណៈ	ចុះកាលអាងត្រពាំងថ្មដូចថាមានចាញ់មានអីទេ កើតជំងឺចាញ់ជំងឺអី?

ម៉ោះ	អត់មានជំងឺចាញ់ទេ មានតែជំងឺរាគមូល ។

វណ្ណៈ	ដោយសារខ្វះជាតិអាហារ?

ម៉ោះ	បាទ!

វណ្ណៈ	ឈឺស្លាប់អញ្ចឹងទៅ?

ម៉ោះ	បាទ! ឈឺស្លាប់ភាគច្រើន ។

វណ្ណៈ	ចុះពេលស្លាប់អីគេកប់ចោលនៅហ្នឹងហ្មង អត់មានហៅបងប្អូនមកយកមកប្រាប់ទេ?

ម៉ោះ	អត់ទេ! ពេទ្យគេដឹកយកទៅកប់នៅកន្លែងណាស្រេចតែគេទៅ អត់មានហៅបងប្អូនណាទៅដឹងពុ្ក បើថាបាត់ក៏បាត់ទៅ មិនដឹងទៅណា ខ្លះរត់ ខ្លះបាត់ខ្លួនទៅអត់មានបងប្អូនណាទៅដឹងពុ្កទេ ។

វណ្ណៈ	អញ្ចឹងពេលមានខ្មោចងាប់ តួនាទីមានតែពេទ្យទេ?

ម៉ោះ	មានតែពេទ្យទេ ហើយសូម្បីតែយើងចល័តនេះងាប់ក៏មិនដឹងធ្វើអីផង ហើយទៅដេកពេទ្យមិនដឹងទៅដេកដល់ណាទេ ហើយចេញពីពេទ្យមិនដឹងទៅដល់ណាទៀត យើងមិនហ៊ានសួរគេ

ទេ បើបាត់ហើយគឺបាត់តែម្តង ដឹងតែស្លាប់ ហើយខ្មោចហ្នឹងមានតួនាទីតែពេទ្យទេ ត្រូវអូស សែងយ៉ាងម៉េចយកទៅកប់ចោលតែគ្នាគេហ្នឹង ហើយដូចថាយើងទាំងអស់គ្នាហ្នឹងឈឺដេកពេទ្យហើយមិនឃើញមកវិញក៏មិនដឹងថាគេដកឲ្យទៅណាដែរ យើងមិនអាចទៅតាមសួរថាអ្នកនេះយ៉ាងម៉េចអ្នកនោះយ៉ាងម៉េចទេ យើងមិនហ៊ានទេ ។

វណ្ណៈ ចុះពូធ្វើអាងត្រពាំងថ្មរួច ពូទៅធ្វើការនៅណាទៀត ឬក៏ចប់នៅហ្នឹងហ្នឹង?

ម៉ៅៈ ខ្ញុំមកធ្វើនៅភ្នំលាភ ។

វណ្ណៈ ធ្វើអីដែរ?

ម៉ៅៈ ធ្វើទំនប់ ប្រុងធ្វើអាង ។

វណ្ណៈ ធ្វើហើយទេអាងហ្នឹង?

ម៉ៅៈ ហើយ ។

វណ្ណៈ អាងហ្នឹងគេហៅអាងអី?

ម៉ៅៈ អាងភ្នំលាភ ។

វណ្ណៈ ប៉ុន្តែធំទេអាងហ្នឹង?

ម៉ៅៈ ខ្ញុំច្រឡំ គេហៅអាងអូរលាភ ។

វណ្ណៈ អូរលាភហ្នឹងធំទេ?

ម៉ៅៈ អូរបន្តិចហ្នឹង កាប់ថ្នល់ខាងលិច ។

វណ្ណៈ ប្រហែលប៉ុន្មានម៉ែត្រ?

ម៉ៅៈ អូរហ្នឹងមិនធំទេ តែបណ្តោយវាវែង ប៉ុន្តែអាងហ្នឹងធំណាស់ អាងហ្នឹងចង់ប៉ុនត្រពាំងថ្មដែរ ។

វណ្ណៈ ហ្នឹងចំណាយមនុស្សលើកច្រើនទេ?

ម៉ៅៈ ដូចគ្នា ដកមនុស្សពីនោះមក ពីភូមិរោងមក ពីភ្នំស្រុកមកទល់ព្រៃមាន់ធ្វើប្រឡាយហ្នឹងធ្វើមួយអាទិត្យ ប្រឡាយហ្នឹងគេធ្វើមួយអាទិត្យហើយ ហើយបានគេលើកអាងហ្នឹង គេដាក់កំណត់ឲ្យយើងមួយអាទិត្យ ។

វណ្ណៈ អាងអូរលាភហ្នឹងធ្វើរយៈពេលប៉ុន្មានដែរ ដល់វៀតណាមចូលមក?

ម៉ៅៈ រយៈពេលឆ្នាំដែលវៀតណាមចូលហ្នឹងឯង ។

វណ្ណៈ ពី៧០ ប៉ុន្មានមក?

ម៉ៅៈ ៧៨-៧៩ ហ្នឹងឯង ។

វណ្ណៈ នៅអាងអូរលោកហ្នឹងមានស្លាប់មនុស្សទេ?

ម៉ៅៈ ស្លាប់ច្រើនដែរហ្នឹង ។

វណ្ណៈ យាយថែម គាត់មានមកកាន់កាប់ខាងអូរលោកហ្នឹងទេ?

ម៉ៅៈ គាត់ក្តាប់មួយស្រុក ។

វណ្ណៈ ក្តាប់មួយស្រុក អញ្ចឹងទាំងអូរលោកហ្នឹងដែរ?

ម៉ៅៈ បាទ!

វណ្ណៈ ស្លាប់ច្រើនដូចអាងត្រពាំងថ្មដែរ?

ម៉ៅៈ ស្លាប់ដូចគ្នា ។

វណ្ណៈ មនុស្សរាប់ម៉ឺននាក់ដូចគ្នា ឬក៏តិចជាង?

ម៉ៅៈ តិចជាងត្រពាំងថ្ម ។

វណ្ណៈ ហើយសព្វថ្ងៃពូដឹង យាយថែម រស់នៅណាទេ?

ម៉ៅៈ យាយថែម មិនដឹងនៅភូមិណាទេ ដឹងតែគាត់រស់នៅ បើអាចទៅម៉ាឡៃ លោកគ្រូបានទៅដល់ម៉ាឡៃសួរថាគាត់នៅភូមិណា គាត់នៅទាំងប្តីទាំងប្រពន្ធ ហើយមនុស្ស យាយថែម ហ្នឹងមិនបានទេ ។

វណ្ណៈ ម៉េចអញ្ចឹង?

ម៉ៅៈ មនុស្សកន្ធិល ។

វណ្ណៈ ទាប?

ម៉ៅៈ មនុស្សមើលមិនបាន សក់ក្រហមប្រិញ ខ្ញុំឃើញកូនចៅពរគ្នាមិនរួចទេ ។

វណ្ណៈ ហើយចុះប្តីគាត់ឈ្មោះអី?

ម៉ៅៈ ឈ្មោះ តាញ៉ែន ។

វណ្ណៈ ប្តីគាត់ឈ្មោះ តាញ៉ែន?

ម៉ៅៈ បាទ! ចៅហ្វាយស្រុកសេរីសោភ័ណ្ឌ ។

វណ្ណៈ ប្តីគាត់ចៅហ្វាយស្រុកដែរ?

ម៉ៅៈ ចៅហ្វាយស្រុក ។

វណ្ណៈ ប្តីគាត់ធំឬក៏តូច មាឌធំឬក៏ល្អិត?

ម៉ៅៈ មាឌធំ ខ្ញុំជួបមិនសូវដែលបាននិយាយគ្នាទេ តែឃើញគាត់មាឌធំ បើ យាយថែម បានមាឌកន្ធៀរ ។

វណ្ណៈ ប្តី យាយថែម នៅរស់ទេរាល់ថ្ងៃ?

ម៉ៅៈ នៅរស់ទាំងអស់គ្នា អញ្ចឹងបានខ្ញុំទៅម៉ាឡៃខ្ញុំសួរដូចថាគាត់ទៅម៉ាឡៃហ្នឹងឯង ។

វណ្ណៈ ឈ្មោះតាអី?

ម៉ៅៈ តាញ៉ែន ។

វណ្ណៈ ជំនាន់ខ្មែរក្រហមចៅហ្វាយស្រុក?

ម៉ៅៈ ចៅហ្វាយស្រុកសេរីសោភ័ណ្ឌយើងនេះ ។

វណ្ណៈ អញ្ចឹង យាយថែម ក្តាប់ស្រុកផ្សេង ហើយប្តីគាត់កាន់ស្រុកផ្សេង?

ម៉ៅៈ បាទ! គាត់កាន់ស្រុកផ្សេងគ្នា ។

វណ្ណៈ ប៉ុន្តែ យាយថែម គាត់កាន់ស្រុកព្រះនេត្រព្រះ?

ម៉ៅៈ បាទ!

វណ្ណៈ ពីដើមគេហៅស្រុកព្រះនេត្រព្រះដែរ?

ម៉ៅៈ បាទ!

វណ្ណៈ ចុះប្តីគាត់កាន់នៅស្រុកសេរីសោភ័ណ្ឌ?

ម៉ៅៈ បាទ!

វណ្ណៈ ម៉េចបានជាពូដឹងថាប្តីគាត់កាន់ស្រុកសេរីសោភ័ណ្ឌ?

ម៉ៅៈ គេនិយាយអញ្ចឹងគ្រប់តែគ្នាហ្នឹង ពួកនារតី ហើយមេៗដែលក្តាប់ខ្ញុំហ្នឹងក៏និយាយថាអញ្ចឹងដែរ តាមខ្ញុំដឹងពីដើមឡើយគាត់កាន់នៅហ្នឹងតើ យាយថែម ហ្នឹង ដល់ពេលនេះវាវល់វិទៅគាត់មក គេដកគាត់មកកាន់នៅនេះឯង ។

វណ្ណៈ ចុះដឹងថាប្តីគាត់ចៅហ្វាយស្រុកដែរ?

ម៉ៅៈ បាទ! ចៅហ្វាយស្រុក ។

វណ្ណៈ ចុះឥឡូវបើពូឃើញ យាយថែម ពូស្គាល់ទេ ស្គាល់មុខគាត់ទេ?

ម៉ៅៈ បើឃើញស្គាល់ តែឃើញស្គាល់ហើយ ។

វណ្ណៈ ចុះពូ ដល់ពេលវៀតណាមចូលឆ្នាំ៧៩ ពូរត់ទៅខាងណាវិញ?

ម៉ៅៈ ខ្ញុំនៅតែនេះឯង គេលែងមកតាមខ្ញុំឲ្យរត់ទៅតាមគេ ខ្ញុំព័ទ្ធទៅនៅតែវាល គេចទៅនៅតាមស្រុកគេ ទាល់តែវៀតណាមចូលរៀបរយតាមភូមិបាន ផុន ហ្នឹងឯងគាត់ជំនាញការ គាត់ឲ្យកាំភ្លើងខ្ញុំឲ្យខ្ញុំជួយផ្ទើឈ្លប ។

វណ្ណៈ ក្រោយ៧៩ហ្នឹងពូ?

ម៉ៅៈ បាទ!

វណ្ណៈ ចុះពូចូលមកដល់ស្រុកកំណើតភូមិវិញ ហើយសព្វថ្ងៃហ្នឹងពូប្រកបមុខធ្វើអីដែរ?

ម៉ៅៈ ធ្វើតែស្រែ ។

វណ្ណៈ បានស្រូវដលគ្រាន់បើទេពូ?

ម៉ៅៈ ធ្វើបានបន្តិចបន្តួចហ្នឹង ធ្វើមិនសូវកើតទេ ស្រែម្នាក់បន្តិចៗ ម្នាក់មួយរ៉ៃហ្នឹង គ្នា៥នាក់ ៥រ៉ៃចែករបបហើយ គ្រាន់តែវាលធំតែមានចែកបានច្រើនណាំ ។

វណ្ណៈ ចុះអ្នកស្រុកអ្នកភូមិនេះ កូនចៅអត់មានការងារធ្វើអញ្ចឹងយើងទៅស៊ីឈ្នួលនៅថៃ ឬក៏យ៉ាង ម៉េចដែរ?

ម៉ៅៈ កូនខ្ញុំទាំងអស់ទៅស៊ីឈ្នួលឲ្យតែថៃហ្នឹង ។

វណ្ណៈ កូនពូទៅប៉ុន្មាននាក់ដែរ?

ម៉ៅៈ កូនខ្ញុំបើគិតទៅមិនបានប្រពន្ធមិនដល់៣-៤នាក់ផង តែ៦នាក់ហ្នឹងទៅទាំងអស់គ្នា វានៅលីវ តែ៤នាក់ទេ ។

វណ្ណៈ ទៅអញ្ចឹងមានទាក់ទងមកពូរាល់ពេលរាល់ខែដែរ កូនចៅនៅថៃហ្នឹង?

ម៉ៅៈ បាទ! មានអី នៅលីវតែ២នាក់ ក្រៅពីនោះបានប្ដីបានប្រពន្ធអស់ហើយ តែនៅតែធ្វើការ នៅនោះដែរ ។

វណ្ណៈ អញ្ចឹងពូដូចថាខ្ញុំសួរសំនួរចុងក្រោយគេ ដូចថាសព្វថ្ងៃហ្នឹងដូចថាពូដែលស្ដាប់រឿងតុលាការ កាត់ទោសរឿង ឌុច រឿងមេដឹកនាំខ្មែរក្រហម ពូមានដែលស្ដាប់ទេ?

ម៉ៅៈ ស្ដាប់ដែរហ្នឹង ខ្ញុំមើលតាមទូរទស្សន៍ ខ្ញុំមើលតែពត៌មានទេ ។

វណ្ណៈ ហើយពូយល់យ៉ាងម៉េចដែរកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹង?

ម៉ៅៈ និយាយរួមឲ្យកាត់អញ្ចឹងចុះ ធ្វើដូចគាត់មិនត្រឹមត្រូវ ។

វណ្ណៈ អញ្ចឹងពូគិតថាការកាត់ទោសហ្នឹងត្រឹមត្រូវហើយ?

ម៉ៅៈ បាទ! បើតាមនិយាយតាមលំដាប់ខ្ញុំ ខ្ញុំជម្រាបលោកគ្រូ គ្រាន់តែកន្លែងទំនប់ដែលខ្ញុំលើក ហ្នឹង គ្រាន់តែរាល់ថ្ងៃខ្ញុំដើរចំក៏ខ្ញុំនឹកឃើញមិនបាត់ដល់ឥឡូវដែរ កាលដែលខ្ញុំធ្លាប់លំបាក កន្លែងហ្នឹងមិនបាច់ ដើរទៅដល់កន្លែងហ្នឹងវាធុញថប់ នឹកឃើញទាំងអស់ដែលគេប្រើគេធ្វើ ម៉េចៗ ចាំអត់ភ្លេចហ្មង ដល់សព្វថ្ងៃនេះដើរចំហ្នឹងនឹកឃើញតែកន្លែងកាលហ្នឹង ដល់ភ្ញាក់ខ្លួន ដូចថាប្រើម៉ែអញឪអញ បើកាលមុនអញបម្រើម៉ែឪអញមិនដឹងគាត់អរប៉ុន្មាន ។

វណ្ណៈ ខ្ញុំភ្លេចសួរពូបន្តិចដែរ កាលដែលពូកាន់៣០០នាក់ហ្នឹងក្ដាប់ទាំងអ្នកថ្មីអ្នកចាស់ដែរ?

ម៉ៅៈ ទាំងអស់ អត់មានគិតថាពីណាពីណីទេ ។

វណ្ណៈ អញ្ចឹងពូ ខ្ញុំដូចជាអស់អីសួរពូហើយ តើពូមានអីចង់និយាយបន្ថែមទៀតទេ?

ម៉ៅៈ អត់មានអីទេ ។

វណ្ណៈ អញ្ចឹងខ្ញុំអរគុណពូច្រើនហើយ ដែលបានផ្ដល់បទសម្ភាសន៍ដើម្បីទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮពីប្រវត្តិសាស្ត្រខ្មែរយើង ។

ម៉ៅៈ ខ្ញុំចាំមិនសូវច្បាស់ ព្រោះវាងយូចង់ភ្លេច ភ្លេចអាមេៗហ្នឹង ។

វណ្ណៈ ២០-៣០ឆ្នាំហើយ ។

ម៉ៅៈ វាធុញដូចខ្ញុំថាអញ្ចឹង វាលែងចង់ឃើញ គ្រាន់តែទៅឃើញកន្លែងធ្វើការវានឹកឃើញសព្វដល់ពេលអញ្ចឹងវាម៉្លៃម៉ៅ ។

វណ្ណៈ អញ្ចឹងខ្ញុំអរគុណពូច្រើនហើយ ។

«ចប់»